**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៤០៩/១៣ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក ណាន់ សុង តំណាងសហគមន៍ជនជាតិដើមភាគតិច គ្រឹង**

**ភូមិតឺន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិតឺន ឃុំតឺន ស្រុកកូនមុំ

**យោង :**
- លិខិតចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ស្តីពីការសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិតឺន របស់លោក ណាន់ សុង តំណាងសហគមន៍។
- លិខិតលេខ ៣៥៧/១៣ ល.អ.ខ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិតឺន របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិតឺន របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិតឺន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី តាមសំណើ ។ សហគមន៍ជនជាតិដើមភាគតិចគ្រឹង ភូមិតឺន អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអភិវឌ្ឍន៍ជនបទ

ជា សុផារ៉ា

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍

  "ដើម្បីជូនជ្រាប"
- សាលាខេត្តរតនគិរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

  "ដើម្បីមុខការ"
- ឯកសារ - កាលប្បវត្តិ

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com